# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០៦៣ ដនស.សសរ

ថ្ងៃព្រហ. ២រោច ខែអាសាឍ ឆ្នាំវក ព.ស.២៥៦០

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកក្កដា គ.ស.២០១៦

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២៤៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- យោងប្រកាសលេខ ៦៤ ប្រក/ដនស ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីតួនាទី ភារកិច្ចរបស់បណ្តាការិយាល័យចំណុះអង្គភាពថ្នាក់កណ្តាលនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងប្រកាសលេខ ២៣៩ ប្រក/បក ចុះថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានលំនៅឋាន
- យោងប្រកាសលេខ ១៥០ ដនស ប/ប្រក/ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននៃអគ្គាធិការដ្ឋានរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១.** បង្កើតគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ឱម សំអែល** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ឆាយ ឫទ្ធិសែន** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៤. ឯកឧត្តម **សេង ឡូត** | អគ្គនាយករដ្ឋបាល | សមាជិក |
| ៥. ឯកឧត្តម **ឡោ ជាចុង** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ៦. ឯកឧត្តម **ហ៊ុយ ណារ៉ា** | អគ្គនាយកសំណង់ | សមាជិក |
| ៧. ឯកឧត្តម **មេងហុង សុជាតិខេមរ៉ូ** | អគ្គនាយកលំនៅឋាន | សមាជិក |
| ៨. ឯកឧត្តម **វ៉ែន ច័ន្ទសុខខេមរា** | អគ្គាធិការ | សមាជិក |
| ៩. លោក **ឡាយ ផល្លីម** | ប្រធាននាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ | សមាជិក |
| ១០. លោក **ម៉ុខ សុខលាភ** | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | សមាជិកអចិន្ត្រៃយ៍ |
| ១១. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | | សមាជិក |

**ប្រការ ២.** គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានភារកិច្ច÷

១. ណែនាំ និងតាមដានការងារចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនៅគ្រប់អង្គភាពប្រើប្រាស់ក្រោមឱវាទក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២. ត្រួតពិនិត្យ និងចុះហត្ថលេខាលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៣. ធ្វើរបាយការណ៍អំពីលទ្ធផលនៃការជួល ការលក់ និងការដូរចលនទ្រព្យ និងអចលនទ្រព្យ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជូនរាជរដ្ឋាភិបាល

**ប្រការ ៣.** គណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| ១. លោក **ម៉ុខ សុខលាភ** | ប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | ប្រធាន |
| ២. លោក **ឌី ផលា** | អនុប្រធាននាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញកិច្ច | អនុប្រធាន |
| ៣. លោក **ខួន បុណ្ណមី** | ប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ៤. លោក **អ៊ុំ ចន្ទសុវណ្ណា** | ប្រធានការិយាល័យហិរញ្ញកិច្ច | សមាជិក |
| ៥. លោក **ស៊ូ សុខជាតិ** | ប្រធានការិយាល័យផ្គត់ផ្គង់ | សមាជិក |
| ៦. លោក **ប៉ុច គីមហួត** | មន្ត្រីការិយាល័យផ្គត់ផ្គង់ | សមាជិក |

**ប្រការ ៤.** លេខាធិការដ្ឋាន មានភារកិច្ចដូចខាងក្រោម÷

១. ធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ នៅបណ្ដាអង្គភាពថ្នាក់កណ្ដាល និងនៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ដើម្បីសុំការអនុម័ត

ពីគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. ពិនិត្យ និងវាយតម្លៃអំពីបរិមាណ និងគុណភាព ទ្រព្យសម្បត្តិរដ្ឋដែលមានក្នុងឃ្លាំង និងកំពុងប្រើប្រាស់ទាំងអស់ឱ្យបានត្រឹមត្រូវច្បាស់លាស់តាមស្ថានភាពជាក់ស្តែងនីមួយៗ។

៣. ពិនិត្យ និងវាយតម្លៃអំពីបរិមាណ និងគុណភាព ទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើការជម្រះបញ្ជី ឬផ្ទេរទៅអង្គភាពខាងក្រៅ ដើម្បីសុំការពិនិត្យនិងសម្រេចពីគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៤. ធ្វើរបាយការណ៍អំពីលទ្ធផលនៃការជួល ការលក់ និងការផ្លូវចលនទ្រព្យ និងអចលនទ្រព្យរបស់រដ្ឋជូនគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

៥. រាយការណ៍ជាប្រចាំជូនគណៈកម្មការបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នូវរាល់សកម្មភាពនិងលទ្ធផលការងារដែលបាននិងកំពុងអនុវត្ត។

**ប្រការ ៥.** សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្រុមការងារមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទឱ្យជួយការងារតាមការចាំបាច់។

**ប្រការ ៦.** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៧.** នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនិងសាមីខ្លួន ដូចរាយនាមក្នុងប្រការ ១ និងប្រការ ៣ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- មន្ទីរ ដ.ន.ស.ស. រាជធានី ខេត្ត ទាំង ២៥
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ